**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ ព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជំនួបពិភាក្សាការងារជាមួយគណៈប្រតិភូនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)

នាព្រឹកថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលដឹកនាំដោយលោក Yasuhisa Ojima អ្នកតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាបានស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូគយនៃមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងបានថ្លែងអំណរគុណនិង វាយតម្លៃខ្ពស់ចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងការផ្តល់ជំនួយបច្ចេកទេសជូនព្រះរាជាណាចក្រកម្ពុជា ជាពិសេសការផ្តល់ជំនួយបច្ចេកទេសក្នុងការអនុវត្តកម្មវិធីកំណែទម្រង់និងទំនើបកម្មរបស់រដ្ឋបាលគយកម្ពុជា និងការកសាងសមត្ថភាពមន្ត្រីគយនិងរដ្ឋាករ តាំងពីឆ្នាំ២០០៣រហូតមកដល់បច្ចុប្បន្ន។

ក្នុងឱកាសជំនួបនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអបអរសាទរយ៉ាងកក់ក្តៅចំពោះលោក William E. LeDrew ដែលត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាប្រទាននូវគ្រឿងឥស្សរិយយសថ្នាក់ **មហាសេនា** តាមរយៈការស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា លោក William E. LeDrew ជាអ្នកជំនាញការរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ អមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អគរ) ទាំងរយៈពេលខ្លី និងរយៈពេលវែង ចាប់តាំងពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០១៩។

ក្នុងតួនាទីជាអ្នកជំនាញការ លោកបានចូលរួមចំណែកទាំងកម្លាំងកាយចិត្ត និងសមត្ថភាពជំនាញ រហូតធ្វើឱ្យការអនុវត្តកម្មវិធីកំណែទម្រង់និងទំនើបកម្មរបស់ អគរលើច្រើនវិស័យ ជាពិសេសពាក់ព័ន្ធនឹងការកសាងបទប្បញ្ញត្តិ និងគោលនយោបាយរបស់ អគរ ទទួលបានជោគជ័យគួរជាទីមោទនៈ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មានប្រសាសន៍ថា តាមរយៈគុណបំណាច់ដ៏ធំធេងនេះ លោក William E. LeDrew ពិតជាសក្តិសមនឹងទទួលនូវគ្រឿងឥស្សរិយយសនេះ។